# សេចក្តីប្រកាសពីគោលបំណង
# ស្តីពី
# ការគាំទ្រដល់គម្រោងធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលតទៅនេះហៅថា "ក្រសួង"
និងអង្គការអន្តរជាតិខាងការងារ

## ប្រកាស

ការតាំងចិត្ត និងឆន្ទៈរបស់ខ្លួន ក្នុងការធ្វើការរួមគ្នា ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុង ឧស្សាហកម្មកាត់ដេរ តាមរយៈការច្របាច់បញ្ចូលគ្នានូវការផ្តល់ប្រឹក្សាយោបល់ផ្នែកគោលនយោបាយ និងការកសាងសមត្ថភាពនៅកម្រិតថ្នាក់ចំនួនបី៖ ថ្នាក់ជាតិ ថ្នាក់ឧស្សាហកម្ម និងថ្នាក់សហគ្រាស និងធ្វើកិច្ចការនេះតាមរយៈកិច្ច សហការផ្នែកបច្ចេកទេសនៃគម្រោងដែលមានឈ្មោះថា **"ការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា"** ដែលតទៅនេះហៅថា "គម្រោង" ។ គម្រោងនេះ បានទទួលហិរញ្ញប្បទានពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត (SIDA) និងក្រុមហ៊ុនម៉ាក Hennes & Mauritz (H&M) និងប្រតិបត្តិដោយអង្គការអន្តរជាតិខាងការងារ។

គម្រោងនេះនឹងមានរយៈពេល ៣ ឆ្នាំ ហើយនឹងមានថវិកាសរុបចំនួន ៨៣៩.៨២៧ ដុល្លារ។ គោលដៅនៃគម្រោង គម្រោងការលម្អិតជាក់លាក់ ផ្នែកផ្សំធាតុចូល និងថវិកា ត្រូវបានពិពណ៌នានៅក្នុងឯកសារគម្រោងលេខ CMB/ 13/ 03/MUL ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣។

ការអនុវត្តនូវគម្រោងនឹងធ្វើឡើងស្របទៅតាមឯកសារគម្រោងដែលធ្វើសេចក្តីព្រាងដោយអង្គការអន្តរជាតិខាងការងារដោយមានកិច្ចសហការ និងពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធ។

ការអនុវត្តន៍នូវគម្រោងនេះ នឹងមានការចូលរួមពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការនិយោជក និងអង្គការសហជីព។ ក្នុងចំណោមការងារដែលត្រូវអនុវត្ត គម្រោងនឹងៈ

- បន្តផ្តល់ប្រឹក្សាយោបល់ផ្នែកគោលនយោបាយ និងជំនួយបច្ចេកទេស តាមការស្នើសុំរបស់ក្រសួង
- បន្តកសាងសមត្ថភាពដៃគូពាក់ព័ន្ធ ជាពិសេសកិច្ចសហការនៅកន្លែងធ្វើការ ការចរចាចុះអនុសញ្ញារួម និងការផ្សះផ្សា
- ពិគ្រោះយោបល់ជាមួយនឹងក្រសួង ដើម្បីរៀបចំលក្ខខណ្ឌយោងសម្រាប់ធ្វើបច្ចុប្បន្នភាព និងបង្កើនគុណភាព ប្រព័ន្ធទិន្នន័យមូលដ្ឋានដែលមានស្រាប់ និងការធ្វើបច្ចុប្បន្នភាពកំណត់ត្រា ស្តីពីការចុះបញ្ជិកាសហជីព ការបញ្ជាក់ភាពជាតំណាងបំផុត និងការចុះបញ្ជិកាអនុសញ្ញារួមទាំងអស់ទៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋាន និងចេញជារបាយការណ៍សម្រាប់ភាគីពាក់ព័ន្ធ
- សហការជាមួយក្រសួង ដើម្បីរៀបចំគេហទំព័រ (Web Interface) ដែលអនុញ្ញាតឱ្យទិន្នន័យខាងលើនេះអាចរកបានជាសាធារណៈ
- ពិនិត្យឡើងវិញលើនីតិវិធីផ្សះផ្សា ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្សះផ្សាតាមការស្នើសុំរបស់ក្រសួង និងចុះផ្សព្វផ្សាយផ្ទាល់ដល់កម្មករនិយោជិត និងនិយោជក ដើម្បីបង្កើនជំនឿទុកចិត្តនៅក្នុងប្រព័ន្ធផ្សះផ្សាវិវាទ
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីក្រសួង កម្មករនិយោជិត និយោជក និងភាគីពាក់ព័ន្ធ ដើម្បីជានាឱ្យមានការយល់ដឹងដូចគ្នាសម្រាប់គ្រប់ភាគីពាក់ព័ន្ធនឹងការអនុវត្តន៍វិធាន ប្រកាស និងបទប្បញ្ញត្តិនានាដែលកំពុងមានប្រសិទ្ធភាពអនុវត្ត។

កាតព្វកិច្ចរបស់អង្គការអន្តរជាតិខាងការងារដែលមាននៅក្រោមគម្រោង នឹងអាស្រ័យទៅលើការទទួលបាននូវមូលនិធិចាំបាច់។ ប្រសិនបើមិនទទួលបានមូលនិធិ ជំនួយបច្ចេកទេសដែលនឹងត្រូវផ្តល់ ឬសកម្មភាពដែលបានគ្រោងទុករបស់គម្រោង អាចនឹងកាត់បន្ថយ ព្យួរ ឬបញ្ចប់ដោយអង្គការអន្តរជាតិខាងការងារ ជាមួយនឹងសុពលភាពភ្លាមៗ។ នៅក្នុងករណីនេះ អង្គការអន្តរជាតិខាងការងារ ត្រូវជូនដំណឹងដល់ក្រសួងជាលាយលក្ខណ៍អក្សរ។

អង្គការអន្តរជាតិខាងការងារ នឹងរៀបចំនូវរបាយការណ៍អំពីសម្ភារបរិក្ខារដែលបានទិញដោយអង្គការអន្តរជាតិ ខាងការងារសម្រាប់គម្រោងក្នុងរយៈពេល ៣០ ថ្ងៃ នៃការបិទគម្រោង។ សម្ភារទាំងនោះ នឹងត្រូវលុបចោលស្របទៅ តាមវិធាន បទប្បញ្ញត្តិ និងបទបញ្ជាណែនាំទាំងឡាយរបស់អង្គការអន្តរជាតិខាងការងារ និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយនឹងម្ចាស់ជំនួយ ។

| | | |
|---|---|---|
| **ឯកឧត្តម អ៊ិត សំហេង**<br>រដ្ឋមន្ត្រី | ហត្ថលេខាតាងនាមឱ្យក្រសួង | ថ្ងៃទី ១២ មិថុនា ២០១៤ |
| Maurizio Bussi<br>នាយកស្តីទីប្រចាំប្រទេស<br>ថៃ កម្ពុជា និងសាធារណរដ្ឋឡាវ | ហត្ថលេខាតាងនាមឱ្យ<br>អង្គការអន្តរជាតិខាងការងារ | ថ្ងៃទី ១២ មិថុនា ២០១៤ |

International
Labour
Organization

# DECLARATION OF INTENT

# ON

# SUPPORT TO IMPROVING INDUSTRIAL RELATIONS IN CAMBODIA'S GARMENT INDUSTRY

The Ministry of Labour and Vocational Training hereafter referred to as "The Ministry" and the International Labour Organization,

## Declare

Their commitment and willingness to work together in order to improve industrial relations in the garment industry through a mixture of policy advice and capacity building at three levels: at the national level, at the industry level, and at the enterprise level and to do so through the technical cooperation project entitled "Improving Industrial Relations in Cambodia's Garment Industry", hereafter referred to as "Project", to be financed jointly by the Swedish International Development Agency (SIDA) and Hennes & Mauritz (H&M), and to be executed by the International Labour Organization.

This project will have an overall duration of 3 years and will have a total budget of US$ 839,827. The objectives of the project, specific details on project design, component inputs and budgets are described in the Project Document ref. CMB/13/03/MUL dated 25 October 2013.

Implementation of the Project will take place in compliance with the Project Document, which has been drafted by ILO in cooperation and consultation with the relevant stakeholders. The implementation of this Project shall involve the Ministry of Labour and Vocational Training and employers' and workers' organizations. The Project will, amongst others:

- continue providing policy advice and technical assistance, on the request by the Ministry;
- continue building capacity of stakeholders, in particular in workplace cooperation, collective bargaining and conciliation;
- in consultation with the Ministry, develop TORs for upgrading and updating database, and for the Ministry to update all records on union registrations, MRS certifications, and CBA registrations in database and issue reports to stakeholders;

- in cooperation with the Ministry, develop web interface to allow public access to database;

- review conciliation procedures with a view to increasing effectiveness of conciliation on the request from the Ministry, and hold outreach sessions with workers and employers to improve confidence in conciliation system;

- hold consultation meetings with MOLVT officials, workers employers, and other relevant stakeholders as to ensure that everyone have common understanding regarding application of rules, and procedures [Prakas and regulations] in force.

The ILO's obligations under the Project shall be contingent upon receipt of the necessary funds. If funds are not received, the assistance to be provided by, or planned activities of the Project may be reduced, suspended or terminated by the ILO with immediate effect. In this event, the ILO shall notify in writing the Ministry.

The ILO shall prepare a report of non-expendable equipment purchased by the ILO for the Project within 30 days of its closure. It shall be disposed of in accordance with the ILO's regulations, rules and directives, and after consultation with the donors.

______________________________ Signed on behalf of the Ministry
Ith Sam Heng
Minister

Date 12 JUNE 2014

______________________________ Signed on behalf of the International Labour Office
Maurizio Bussi
Country Director for Thailand, Cambodia and Lao PDR

Date 12 JUNE 2014